អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

# សុន្ទរកថាថ្លែងបើក
# អនុប្រធានអន្តរជាតិ លោកស្រីចៅក្រម Silvia Cartwright
# ក្នុងកិច្ចប្រជុំពេញអង្គលើកទី ៧ របស់ អ.វ.ត.ក
# នៅថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០១០

សូមគោរពឯកឧត្តមប្រធាន គង់ ស្រ៊ីម ចៅក្រម និងលោក-លោកស្រីទាំងអស់ជាទីគោរព។ ខ្ញុំសូមចូលរួមជាមួយលោកប្រធានក្នុងការស្វាគមន៍ដល់ចៅក្រម និងសហព្រះរាជអាជ្ញានៃ អ.វ.ត.ក ព្រមទាំងមន្ត្រីដទៃទៀតដែលនឹងអញ្ជើញចូលរួមក្នុងកិច្ចប្រជុំពេញអង្គលើកទី ៧ នៅក្នុងសប្តាហ៍ខាងមុខនេះ។

លោកប្រធាន វាជាការគួរឲ្យរីករាយណាស់ចំពោះការស្វាគមន៍ជាពិសេស ដល់សហព្រះរាជអាជ្ញាអន្តរជាតិ និងសហព្រះរាជអាជ្ញាបម្រុងរបស់គាត់។ យើងទាំងអស់គ្នានឹងមានទំនាក់ទំនងប្រកបដោយផ្លែផ្កាជាមួយពួកគាត់។

ខ្ញុំក៏សូមសម្តែងអំណរគុណផងដែរដល់សហការីរបស់យើង គឺចៅក្រម Downing ចៅក្រម Marchi-Uhel ចៅក្រម Lahuis និងចៅក្រម Mumba ចំពោះឆន្ទៈរបស់ពួកគាត់ក្នុងការទទួលយកការទទួលខុសត្រូវថ្មីជាចៅក្រមពេញសិទ្ធិ ឬចៅក្រមបម្រុង នៅក្នុងអង្គបុរេជំនុំជម្រះ និងអង្គជំនុំជម្រះតុលាការកំពូល។ ក្រោមការដឹកនាំរបស់ ឯ.ឧ ចៅក្រម ប្រាក់ គឹមសាន ខ្ញុំសូមជូនពរដល់សមាជិកទាំងអស់នៃអង្គបុរេជំនុំជម្រះ ដោយសារពួកគាត់ប្រឈមនឹងបញ្ហាជាច្រើន ដែលនឹងមាននៅចំពោះមុខពួកគាត់។

លោកប្រធានជាទីគោរព នៅក្នុងកិច្ចប្រជុំពេញអង្គលើកចុងក្រោយ ខ្ញុំបានលើកឡើងថា វាចាំបាច់នៅក្នុងតុលាការអន្តរជាតិទាំងឡាយដែលត្រូវធានា នៅក្នុងវង្វង់បទដ្ឋាននៃភាពត្រឹមត្រូវនៃការជំនុំជម្រះ ថា នីតិវិធី

ដែលបង្កើតឡើងនោះត្រូវតែវិវឌ្ឍន៍ ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ប្រជាជន។ ចំណុចនេះមានសារៈសំខាន់ណាស់សម្រាប់ប្រជាជនកម្ពុជាដែលគិតថា ការជំនុំជម្រះទាំងនេះពិតជាសំខាន់មែន។

ដោយសារតែហេតុផលនេះហើយដែល អ.វ.ត.ក បានអនុម័តជាលើកដំបូងនូវវិធានផ្ទៃក្នុង ដែលបង្កលក្ខណៈឲ្យជនរងគ្រោះចូលរួមនៅក្នុងសវនាការជាដើមបណ្តឹងរដ្ឋប្បវេណី។ នេះជាចំណុចធម្មតានៅក្នុងប្រព័ន្ធច្បាប់ស៊ីវិល រួមទាំងប្រព័ន្ធច្បាប់របស់កម្ពុជាផងដែរ ប៉ុន្តែ វាមិនមែនជាទិដ្ឋភាពនៃការជំនុំជម្រះនៅកម្រិតអន្តរជាតិនោះទេ។ ឥឡូវនេះ អ.វ.ត.ក បានបញ្ចប់កិច្ចស៊ើបសួរពេញលេញមួយដំណាក់ហើយ ដំណាក់កាលមុនការជំនុំជម្រះ និងដំណាក់កាលជំនុំជម្រះសម្រាប់សវនាការលើកដំបូង និងបទពិសោធន៍ដែលទទួលបានបង្ហាញពីសារៈសំខាន់ចំពោះការប្រឹងប្រែងរបស់យើងដើម្បីធានាថា ការចូលរួមពាក់ព័ន្ធរបស់ជនរងគ្រោះជាដើមបណ្តឹងរដ្ឋប្បវេណី គឺជាបទពិសោធន៍មានសារៈប្រយោជន៍សម្រាប់ពួកគាត់ ហើយក៏ធ្វើឲ្យប្រសើរឡើងដល់គុណភាពនៃការជំនុំជម្រះនេះផ្ទាល់ផងដែរ។

អ.វ.ត.ក ពិចារណាឃើញថា ការចូលរួមពាក់ព័ន្ធរបស់ជនរងគ្រោះនៅក្នុងការជំនុំជម្រះ ពិតជាមានសារៈសំខាន់បំផុត។ ដូចយើងទាំងអស់គ្នាដឹងហើយថា ចំនួនចុងក្រោយនៃជនរងគ្រោះដែលមានបំណងធ្វើជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសវនាការលើសំណុំរឿង ០០២ គឺមាន ៤.០០៤ នាក់។ ហេតុដូច្នេះ វាច្បាស់ហើយថា ចំនួននេះគឺពិតជាលើសពីសមត្ថភាពរបស់អង្គជំនុំជម្រះសាលាដំបូង ដែលត្រូវពាក់ព័ន្ធជាមួយនឹងពួកគាត់ម្នាក់ៗហើយ។

លោកប្រធាន ដូចលោកបានលើកឡើងហើយថា វាចាំបាច់ណាស់ដែលត្រូវស្វែងរកមធ្យោបាយនានាដើម្បីធានាថា តួនាទីរបស់ដើមបណ្តឹងរដ្ឋប្បវេណីអាចត្រូវបានរក្សាទុក។ ដូចលោកបានបញ្ជាក់ថា តាមគំនិតយោបល់របស់យើង កិច្ចប្រជុំពេញអង្គលើកចុងក្រោយបានអនុម័តនូវវិធាននានា ដែលនឹងមានដំណើរការវែងឆ្ងាយឆ្ពោះទៅកាន់ការធានាដល់ការចូលរួមរបស់ជនរងគ្រោះជាបន្តទៅទៀត។ អនុគណៈកម្មាធិការដែលបានទទួលភារកិច្ចឲ្យផ្តល់អនុសាសន៍លើការកែប្រែវិធានផ្ទៃក្នុងជាលម្អិត ដើម្បីធ្វើឲ្យមានអានុភាពដល់គោលការណ៍ទូលំទូលាយ ដែលបានអនុម័តដោយកិច្ចប្រជុំពេញអង្គនោះ បានពិភាក្សាយ៉ាងច្រើនជាមួយសង្គមស៊ីវិល មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងផ្នែកផ្សេងទៀតនៃតុលាការនេះ ទៅលើមធ្យោបាយប្រសើរបំផុតដើម្បីធ្វើឲ្យនីតិវិធីថ្មីនេះមានអានុភាព។ យើងសូមថ្លែងអំណរគុណដល់អ្នកទាំងអស់ដែលបានចូលរួម និងសូមអគុណចំពោះសំណើ និងមតិយោបល់ជាច្រើនដែលមានសារៈប្រយោជន៍។

អ្វីដែលមានសារៈសំខាន់បំផុតនោះគឺ សំណើសុំឲ្យមានលក្ខណៈប្រសើរឡើងលើការទទួលខុសត្រូវរបស់អង្គភាពគាំពារជនរងគ្រោះ។ ដោយសារតែត្រូវបានដាក់ឈ្មោះថ្មីថាជា ផ្នែកគាំពារជនរងគ្រោះ នោះផ្នែកនេះបន្តគាំទ្រផ្នែករដ្ឋបាលដល់ដើមបណ្តឹងរដ្ឋប្បវេណី ប៉ុន្តែនឹងមានអាណត្តិកាន់តែទូលំទូលាយដើម្បីរៀបចំ និងអនុវត្តកម្មវិធី និងវិធានការនានា ដែលនឹងផ្តល់ផលប្រយោជន៍ដល់ជនរងគ្រោះទាំងអស់ ទោះបីពួកគាត់ជាដើមបណ្តឹងរដ្ឋប្បវេណី ឬមិនមែនដើមបណ្តឹងរដ្ឋប្បវេណីក្តី។ យើងជឿជាក់ថា ចំណុចនេះនឹងក្លាយជាកេរក្តិ៍ដំណែលចម្បងមួយរបស់សាលាក្តីនេះ។

យើងទាំងអស់គ្នាជ្រាបហើយថា មានបញ្ហាពិសេសៗជាច្រើនដែលអង្គជំនុំជម្រះនានាកំពុងតែប្រឈមៈ ពេលវេលាចាប់តាំងពីពេលដែលអំពើឧក្រិដ្ឋបានកើតឡើង ហើយជាលទ្ធផល គឺអាយុរបស់ជនជាប់ចោទតែម្តង។ ទោះយ៉ាងណាក្តី សំខាន់បំផុតនោះគឺចំនួនសរុបនៃអ្នកដែលបានរងការប៉ះពាល់ដោយផ្ទាល់ ឬដោយប្រយោល។ អ្នកទាំងនោះរួមមាន ចាប់ពីអ្នកដែលមានចំណេះជ្រៅជ្រះ និងអ្នកមាន រហូតដល់កសិករក្រីក្របំផុតដែលមានការចេះដឹងតិចតួច, ចាប់ពីអ្នករស់នៅក្រៅប្រទេស រហូតដល់អ្នកលំបាកលំបិនរស់នៅតាមជនបទ ឬនៅតាមទីក្រុងនានានៃប្រទេសកម្ពុជា។ ប្រជាជនជាច្រើននាក់មានសុខភាពយ៉ាប់យ៉ឺន ហើយភាគច្រើនភ័យខ្លាចដោយសារតែអ្វីដែលពួកគាត់បានជួបប្រទះ។ ពួកគាត់មានចំនួនដល់ទៅរាប់សិបពាន់នាក់ មិនមែនរាប់រយនាក់ ឬប្អូនដប់នាក់នោះទេ។ វាចាំបាច់ណាស់ដែលសំឡេងរបស់ពួកគាត់ និងរឿងរ៉ាវនៃការឈឺចាប់របស់ពួកគាត់ក្លាយជាផ្នែកមួយនៃកិច្ចដំណើរការនីតិវិធីរបស់ អ.វ.ត.ក។

ដើម្បីសម្រេចបែបនេះបាន ដោយមិនធ្វើឲ្យប៉ះពាល់ទាំងស្រុងដល់ការជំនុំជម្រះ យើងបានទទួលស្គាល់ថានីតិវិធីត្រូវតែវិវត្តន៍។ វាជាការថ្លឹងថ្លែងលើបញ្ហាច្បាប់ និងនីតិវិធីដែលស្មុគស្មាញ ដែលត្រូវសម្រេចឲ្យបាន ហើយខ្ញុំជឿជាក់ថា លទ្ធផលនេះនឹងមានសារៈប្រយោជន៍សម្រាប់តុលាការដទៃទៀត ដែលអាចប្រឈមនឹងបញ្ហាដូចគ្នានេះនៅពេលអនាគត។

កិច្ចប្រជុំពេញអង្គនេះផ្តោតទាំងស្រុងទៅលើកាផានាថា សេចក្តីព្រាងវិធានផ្ទៃក្នុងដែលបានរៀបចំ ក្រោយពីមានការពិគ្រោះយោបល់ទាំងនោះរួចមក ត្រូវបានយកមកពិចារណា ហើយប្រសិនបើចាំបាច់ ត្រូវតែសម្រួលឡើងវិញ និងត្រូវអនុម័តឲ្យបានទាន់ពេលវេលា ដើម្បីយកមកអនុវត្តឲ្យបានពេញលេញនៅក្នុងសវនាការលើកទីពីរ។ វាជាសេចក្តីរំពឹងទុករបស់យើងថា វិសោធនកម្មទៅលើវិធានផ្ទៃក្នុងដែលបានអនុម័តនៅក្នុងសប្តាហ៍នេះ នឹងជួយលើកស្ទួយដល់តួនាទីដ៏សំខាន់ដែលជនរងគ្រោះបានបំពេញនៅក្នុងសវនាការរួចទៅហើយ។

សូមអរគុណឯកឧត្តម ដែលបានផ្តល់ឱកាសឲ្យខ្ញុំថ្លែងទៅកាន់សមាជិកទាំងអស់នៃកិច្ចប្រជុំពេញអង្គ និង សាធារណៈជនដែលបានបង្ហាញចំណាប់អារម្មណ៍ក្នុងកិច្ចដំណើរការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក ជាយូរមកហើយ និងអ្នកដែលចែករំលែកនូវបំណងរបស់យើងដើម្បីធានាថា ការជំនុំជម្រះទាំងនេះនឹងបន្តមានភាពត្រឹមត្រូវ និងតម្លាភាព មិនមែនសម្រាប់តែជនជាប់ចោទនោះទេ តែក៏សម្រាប់ជនរងគ្រោះរាប់សិបពាន់នាក់ដែលមានចំណាប់អារម្មណ៍យ៉ាងខ្លាំងចំពោះលទ្ធផលនៃការកាត់សេចក្តីនេះ។

(ចប់)

* ពិធីស្បថចូលកាន់មុខតំណែងរបស់សហព្រះរាជអាជ្ញាអន្តរជាតិ លោក Andrew Cayley និងសហព្រះរាជអាជ្ញាអន្តរជាតិបម្រុងរបស់គាត់ លោក Nicholas Koumjian បានធ្វើឡើងភ្លាមៗ បន្ទាប់ពីការថ្លែងសុន្ទរកថារបស់លោកស្រីរួចមក។